**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៤៥.ណស

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៧

សូមគោរពជូន

**ឯកឧត្តម ថោងលន់ ស៊ីសូលីត**

**នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

**កម្មវត្ថុ៖** សំណើស្នើឲ្យរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដកកងកម្លាំងប្រដាប់អាវុធ ចេញពីតំបន់ក្បែរអូរអាឡៃ និងតំបន់អូរតាង៉ាវ ព្រំដែនខេត្តស្ទឹងត្រែង និងខេត្តអាតាពើ ឡាវ។

**ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់**

តាមការឯកភាពរវាង**ឯកឧត្តម** និងខ្ញុំ ក្នុងឱកាសនៃកិច្ចប្រជុំ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញកន្លងមក ប្រធានគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរកម្ពុជា-ឡាវ នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧ បានចុះត្រួតពិនិត្យទីតាំងជាក់ស្តែង ការសាងសង់ផ្លូវដោយកងវិស្វកម្មកម្ពុជា នៅតាមបណ្តោយទន្លេសេកុង ក្បែរតំបន់អូរអាឡៃ និងនៅតំបន់ដែលទាហានឡាវបោះទីតាំង នៅអូរតាង៉ាវ ស្រុកសៀមប៉ាង ព្រំដែនខេត្តស្ទឹងត្រែង និងខេត្តអាតាពើ នោះមក បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ទាហានឡាវ ពិតជាបានរំលោភអធិបតេយ្យភាព និងបូរណភាពទឹកដីកម្ពុជានៅតំបន់ខាងលើនោះពិតប្រាកដមែន (ឧបសម្ព័ន្ធ ១) ហើយរហូតមកដល់ពេលនេះ ភាគីមិត្ត នូវពុំទាន់បានដកកម្លាំងប្រដាប់អាវុធ ចេញពីទឹកដីកម្ពុជានៅឡើយ ទោះបីជាកម្ពុជាបានផ្អាកការធ្វើផ្លូវ និងបានដកគ្រឿងចក្រចេញពីតំបន់នោះហើយក៏ដោយ។

**ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់**

ដូចដែល **ឯកឧត្តម** ជ្រាបហើយថា ប្រទេសយើងទាំងពីរបានជ្រើសរើសផ្លូវដ៏ត្រឹមត្រូវមួយក្នុងការកសាងព្រំដែនរវាងប្រទេសយើងទាំងពីរ តាមរយៈការចរចាដោយសន្តិភាព មិត្តភាព និងសហប្រតិបត្តិការជិតខាងល្អ ដែលមានជាយូលង់ណាស់មកហើយ។ យោងលើស្មារតីនេះ ប្រទេសយើងទាំងពីរបានធ្វើការត្រួតពិនិត្យខ្សែព្រំដែននៅលើដីជាក់ស្តែងបានចំនួន ៤៦៤.៥ គម លើខ្សែព្រំដែន

ដែលមានប្រវែងប្រមាណជា ៥៤០ គម ស្មើនឹង ៨៦ % នៃខ្សែព្រំដែនរួម និងបានបោះបង្គោលព្រំដែន បានចំនួន ១២១ លើចំនួនសរុប ១៤៥ បង្គោល នៅសល់ ១៤ %ទៀត កំពុងបន្តការចរចាដោះស្រាយ។ សមិទ្ធិផលទាំងអស់នេះ កើតចេញមកពីការខិតខំប្រឹងប្រែង រកដំណោះស្រាយតាមរយៈការពិភាក្សាគ្នា ត្រង់ទៅត្រង់មក យោគយល់គ្នា ក្នុងនាមជាប្រទេសភូមិផងរបងជាប់គ្នា និងដោយបានការឯកភាពគ្នាជាឯកច្ឆន្ទ ទទួលយកទាំងស្រុងគោលការណ៍ខ្សែព្រំដែនមិនកែប្រែ ដែលបន្សល់ទុកដោយអាណានិគម ដូចមាននៅលើផែនទី Bonne ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន រួមនិងការទទួលស្គាល់ជាអន្តរជាតិក្នុងការកសាងព្រំដែនរវាងប្រទេសយើងទាំងពីរ។

## ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់

តាមការផ្ទៀងផ្ទាត់នៅទីតាំងជាក់ស្តែង ជាមួយនឹងផែនទីផ្លូវការ ឧបសម្ព័ន្ធ៤ នៃកំណត់ហេតុកិច្ចប្រជុំលើកទី២ របស់គណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៧ និងឯកសារផែនទីដែលបានឯកភាពគ្នានាឆ្នាំបន្តបន្ទាប់មកទៀត ក្នុងនោះ ភាគីទាំងពីរបានអនុម័តយកផែនទីសមស្រប ចំនួន ១១ ផ្ទាំង ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ដើម្បីធ្វើជាមូលដ្ឋានបង្អែកក្នុងការកសាងព្រំដែនរវាងប្រទេសទាំងពីរ។ ក្នុងចំណោមផែនទីទាំង១១ ផ្ទាំងៗឈ្មោះ PHIAFAY (EST) លេខ ១៤៦ E ផលិតឆ្នាំ ១៩៥៥ (ឧបសម្ព័ន្ធ ២) បានបង្ហាញយ៉ាងច្បាស់ថា តំបន់អូរតាង៉ាវ និងតំបន់ដែលកម្ពុជាសាងសង់ផ្លូវនៅតាមបណ្តោយទន្លេសេកុងនោះ គឺស្ថិតនៅយ៉ាងជ្រៅ ចម្ងាយ ពី២០០ ទៅ ៧០០ម ក្នុងទឹកដីកម្ពុជា ដែលមិនគួរណាឡាវ ឆ្លងខ្សែព្រំដែនធម្មជាតិដែលខណ្ឌដោយទន្លេសេកុង មកដីកលេណដ្ឋាន ដាក់ទាហានតាមខ្សែត្រៀម និងរាំងការធ្វើផ្លូវរបស់កម្ពុជានៅត្រើយក្នុងដីកម្ពុជានោះទេ។

បន្ថែមលើនេះទៀត ក្នុងឱកាសនៃកិច្ចប្រជុំរវាងអនុរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ នាថ្ងៃទី០៥/០៦/០៨ ភាគីឡាវបានគូសខ្សែព្រំដែននៅតំបន់ដែលកម្ពុជាកំពុងសាងសង់ផ្លូវនេះ ដើរតាមមាត់ច្រាំងនៃទន្លេសេកុង ដូចមានក្នុងផ្ទាំងផែនទី PHIAFAY ខាងលើ ឲ្យកម្ពុជាទទួលយក តែខុសត្រង់ថាក្នុងផែនទីនោះ ឡាវបានគូសខ្សែព្រំដែនថ្មីមួយទៀតនៅតំបន់អូរតាង៉ាវនេះ ដែលកម្ពុជាមិនអាចទទួលយកបាន ព្រោះខុសពីផែនទីដើម ដែលភាគីទាំងពីរបានអនុម័តយករួចមកហើយ (ឧបសម្ព័ន្ធ ៣)។

ស្តីពីតំបន់អូរតាង៉ាវនេះ ខ្ញុំសូមជម្រាបជូន ថា ភាពស្របច្បាប់នៃអធិបតេយ្យភាពកម្ពុជានៅតំបន់នេះ ត្រូវបានរដ្ឋាភិបាល**ឯកឧត្តម** បានទទួលស្គាល់រួចហើយ តាមរយៈផែនទីបោះពុម្ពដោយក្រុមភូមិសាស្ត្ររដ្ឋ (SERVICE GEOGRAPHIQUE D'ETAT) ផ្ទាំង B.SOMPOY លេខ D-48-XVII Edition 1987 ខ្នាត ១/២០០ ០០០ ដែលបានតម្កល់ទុកនៅវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង (IGN) នាថ្ងៃទី០២/០៦/១៩៩២ (ឧបសម្ព័ន្ធ ៤)។ ទាំងនេះ បានបញ្ជាក់បន្ថែមយ៉ាងច្បាស់ទៀតថា តំបន់អូរ-តាង៉ាវស្ថិតក្នុងបូរណភាពទឹកដីកម្ពុជា ដូចមានក្នុងផែនទី Bonne ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលភាគីទាំងពីរយកធ្វើជាមូលដ្ឋានក្នុងការបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ ដែលសម្រេចបានលទ្ធផល ៨៦% ដូចបានបង្ហាញជូនខាងលើ។

**ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់**

យោងលើចំណងមិត្តភាព សាមគ្គីភាព ជាប្រពៃណីដែលមានជាយូលង់ណាស់មកហើយ និងដើម្បីបន្តថែរក្សាបាននូវសន្តិភាពក្នុងនាមជាប្រទេសជិតខាងល្អ និងដើម្បីជៀសវាងការប្រឈមមុខដាក់គ្នាដោយកម្លាំងប្រដាប់អាវុធដែលអាចនឹងកើតមាននោះ ខ្ញុំសូមស្នើរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដកកងកម្លាំងប្រដាប់អាវុធ ចេញពីតំបន់ក្បែរអូរអាឡៃ និងតំបន់អូរតាង៉ាវ ព្រំដែនខេត្តស្ទឹងត្រែង និងខេត្តអាតាពើ ព្រមទាំងបញ្ឈប់គ្រប់សកម្មភាពដូចមានក្នុងកំណត់ទូតកម្ពុជា លេខ ៩៤៦ MFA-IC/LC4 ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧ ដើម្បីឲ្យសភាពការណ៍មិនប្រក្រតីទាំងអស់នោះវិលទៅរកសភាពដើមវិញ។ ទន្ទឹមនឹងនេះដែរ ជាថ្មីម្តងទៀត **ខ្ញុំ** សូមស្នើរដ្ឋាភិបាលឡាវ ទទួលយកសំណើដំណោះស្រាយ ៤ ចំណុច ដែលនៅសេសសល់ នៅក្នុងខេត្តស្ទឹងត្រែង និងខេត្តចំប៉ាសាក់ ដូចមានក្នុងលិខិតសំណើរបស់ខ្ញុំ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ដើម្បីឲ្យក្រុមជំនាញ នៃគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរ ចុះធ្វើការវាស់វែង និងកំណត់ទីតាំងបង្គោលព្រំដែននៅលើដីជាក់ស្តែងនៅពេលវេលាសមស្រប ដើម្បីឈានទៅបញ្ចប់បញ្ហាព្រំដែនដែលនៅសេសសល់នាពេលខាងមុខ។

**ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់**

តាងនាមឲ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងនូវការកោតសរសើរជាថ្មីម្តងទៀត ចំពោះការខិតខំប្រឹងប្រែង និងការយោគយល់គ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសយើងទាំងពីរ ក្នុងគោលដៅកសាងខ្សែព្រំដែនរវាងប្រទេសយើងទាំងពីរ ឲ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីភាពសុខសាន្តរបស់ប្រទេសជាតិ និងប្រជាជននៃប្រទេសយើងទាំងពីរតរៀងទៅ។

សូម **ឯកឧត្តម នាយករដ្ឋមន្ត្រី** ទទួលនូវសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

សូមជូនភ្ជាប់មកជាមួយនូវផែនទីឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងផែនទីចុះត្រួតពិនិត្យលើដីជាក់ស្តែងចំនួន ០១ ច្បាប់ ។

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**